ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ស្ពឺ**

-សំណុំរឿងរដ្ឋប្បវេណីលេខ ២៨០

ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១

-សាលក្រមលេខ:១៨ (គ)

ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពង់ស្ពឺ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នៅថ្ងៃចន្ទ ៨រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣

ដែលមានសមាសភាពដូចតទៅ៖

**ចៅក្រម**

លោក [redacted] ជាចៅក្រម នៃសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ស្ពឺ

-ដើមចោទឈ្មោះ [redacted] ស្រីមុំ ភេទស្រី កើតថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩៣ ជនជាតិខ្មែរ អាសយដ្ឋាន បច្ចុប្បន្ន[redacted]។

-ដោយមានលោក [redacted] និងលោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ស្រីមុំ មានការិយាល័យតាំងនៅផ្ទះលេខ [redacted]។

-ចុងចម្លើយឈ្មោះ [redacted] សុខអៀង ភេទប្រុស កើតថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨ ជនជាតិខ្មែរ អាសយដ្ឋាន [redacted]។

## អង្គហេតុ និងចំណុចវិវាទ

**១-សាលក្រមដែលដើមចោទទាមទារ៖**

១.១-សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] សុខអៀង។

១.២-សុំសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] ម៉េងហាន ភេទប្រុស កើតថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ និងកូនឈ្មោះ [redacted] ហុងសេង ភេទប្រុស កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨។

១.៣-ប្រគល់ដីកសិកម្មដែលមានវិញ្ញាបនបត្រលេខ: ២១០២១២១០-០៥០៧ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ ឱ្យដើមចោទឈ្មោះ [redacted] ស្រីមុំ។

១.៤-បង្គាប់ឱ្យចុងចម្លើយប្រគល់ប្រាក់ USD ៥០.០០០$ (ប្រាំម៉ឺនដុល្លារសហរដ្ឋអាមេរិក) ឱ្យទៅដើមចោទឈ្មោះ [redacted] ស្រីមុំ ជាប្រាក់លក់ដីលំនៅឋានពុះជាដីឡូត៍បានក្នុង អំឡុងឆ្នាំ២០១៨ ចំនួនលើសពី USD ១០០.០០០$ (ដប់ម៉ឺន) ដុល្លារអាមេរិក ដែលចុងចម្លើយកាន់កាប់។

១.៥-សម្ភារៈផលិតទឹកកកអនាម័យ ធុងផ្សេងៗ រួមទាំងឃ្លាំង និងរថយន្ត៣គ្រឿង មាន តម្លៃ ប្រមាណ USD ១០០.០០០$ (ដប់ម៉ឺន)ដុល្លារអាមេរិក បង្គាប់ឱ្យចុងចម្លើយ ប្រគល់ប្រាក់ USD ៥០.០០០$ (ប្រាំម៉ឺន)ដុល្លារអាមេរិក ឱ្យទៅដើមចោទ ឈ្មោះ [redacted] ស្រីមុំ។

១.៦-ប្រាក់កម្ចីមានការប្រាក់នៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ និងនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ គិតត្រឹមដើមខែធ្នូ ឆ្នាំ២០២១ សរុប ប្រមាណ USD ១៦.៧៤៣,០២$ (មួយម៉ឺនប្រាំមួយពាន់ប្រាំពីររយសែសិបបីដុល្លារ

អាមេរិក និងសូន្យពីរសេន) បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សុខអៀង ជាអ្នកមានកាតព្វកិច្ចសងទាំងអស់។

**២-ការសង្ខេបរឿងក្តី៖**

ដើមចោទបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] សុខអៀង ភេទប្រុស សញ្ញាតិខ្មែរដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់លេខ ១២ ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំជង្រុក ខេត្តកំពង់ស្ពឺ។ នៅក្នុងចំណងដៃរវាងខ្លួន និងចុងចម្លើយ គឺមានកូនចំនួន ២នាក់ មានឈ្មោះ ទី ម៉េងហាន ភេទប្រុស កើតថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ និងឈ្មោះ [redacted] ហុងសេង ភេទប្រុស កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨។ នៅក្នុងកំឡុងអាពាហ៍ពិពាហ៍នេះ ខ្លួន និងចុងចម្លើយ មានទ្រព្យសម្បត្តិរួមដូចជា៖ ដីកសិកម្មដែលមានវិញ្ញាបនបត្រលេខ៖ ២១០២១២១០-០៥០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយមន្ទីរសុរិយោដី នគរូបនីយ៍កម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ, ប្រាក់លក់ដីពុះជាឡូតិ៍ដែលជាទ្រព្យរួមលក់បានក្នុងកំឡុងឆ្នាំ២០១៨ ចំនួនលើសពី USD ១០០,០០០ (ដប់ម៉ឺន)ដុល្លារអាមេរិក ដែលចុងចម្លើយកាន់កាប់ព្រមទាំងសម្ភារៈផលិតទឹកកកអនាម័យរួមទាំងឃ្លាំង និងរថយន្តចំនួន ៣គ្រឿង ដែលមានតម្លៃ ប្រមាណ USD ១០០,០០០ (ដប់ម៉ឺន)ដុល្លារអាមេរិក។ មួយវិញទៀតក្នុងអាពាហ៍ពិពាហ៍របស់ខ្លួន និងចុងចម្លើយ គឺមានជាប់បំណុលរួមដែលជាប្រាក់កម្ចីមានការប្រាក់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត កម្ចីកាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ និងនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ គិតត្រឹមដើមខែធ្នូ ឆ្នាំ២០២១ សរុបប្រមាណ USD ១៦,៧៤៣.០២ (មួយម៉ឺនប្រាំមួយពាន់ប្រាំពីររយសែសិបបីដុល្លារអាមេរិកនិងសូន្យពីរសេន) ដែលខ្លួនកំពុងតែទទួលរ៉ាប់រងសងតែម្នាក់ឯង។ នៅក្នុងអាពាហ៍ពិពាហ៍របស់ខ្លួន រវាងចុងចម្លើយឈ្មោះ [redacted] សុខអៀង តាំងពីរៀបអាពាហ៍ពិពាហ៍មក គឺនៅក្នុងក្រុមគ្រួសាររស់នៅមិនចុះសម្រុងនិងគ្នានោះទេ ចេះតែឈ្លោះប្រកែកគ្នា ខ្វែងគំនិតគ្នា ជាពិសេសទៅទៀតនោះ ភាគីចុងចម្លើយមិនបានគិតខ្វល់ខ្វាយអំពីជីវភាពប្រពន្ធកូនក្នុងគ្រួសារនោះទេ ពោលគឺមិនមានការឧបត្ថម្ភទំនុកបម្រុងចិញ្ចឹមបីបាច់ថែរក្សាកូន និងក្រុមគ្រួសារអោយរីកចម្រើននោះទេ គឺមានតែខ្លួនម្នាក់ឯងគត់ ដែលខិតខំចិញ្ចឹមកូនទាំងពីរនាក់ និងរកស៊ីដោះបំណុលរួម ដែលបានខ្ចីប្រាក់មានការប្រាក់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ហើយចុងចម្លើយបានយកប្រាក់ទាំងនេះទៅរកស៊ីទឹកកកអនាម័យ ដោយមិនបានជួយបង់ការប្រាក់ និងប្រាក់ដើមនោះទេ។ កន្លងមកចុងចម្លើយបានគំរាមកំហែងថា និងអាកសម្លាប់ខ្លួន និងវាយសម្ភារៈផ្ទះបាយ និងសម្ភារៈប្រើប្រាស់ក្នុងផ្ទះ ហើយនៅយប់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ៨ ចុងចម្លើយ បានវាយធ្វើបាបកូនឈ្មោះ [redacted] ហុងសេង ភេទប្រុស កើតឆ្នាំ២០១៨ បណ្តាលអោយបែកឈាមមាត់។ នៅក្នុងអំឡុងឆ្នាំ២០១៨ ខ្លួន និងចុងចម្លើយ បានលក់ដីលំនៅឋានដោយពុះជាឡូតិ៍ បានប្រាក់លើសប្រមាណ USD ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក គឺចុងចម្លើយមិនបានអោយខ្លួនដែលជាប្រពន្ធកាន់កាប់នោះទេ គឺចុងចម្លើយកាន់កាប់តែម្នាក់ឯង និងមិនព្រមយកប្រាក់នោះ ទៅសងបំណុលនោះទេ ទុកអោយខ្លួនរ៉ាប់រងសងតែម្នាក់ឯង។

**៣-ការអះអាងរបស់ភាគី៖**

៣.១-ដើមចោទឈ្មោះ [redacted] ស្រីម៉ី បានធ្វើសេចក្តីថ្លែងការណ៍ថា៖ សុំឱ្យតុលាការចេញសាលក្រមសម្រេចដូចការទាមទារក្នុងកម្មវត្ថុខាងក្រោម៖

-សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] សុខអៀង។

-សុំសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] ម៉េងហាន ភេទប្រុស កើតថ្ងៃទី០៦ ខែតុលាឆ្នាំ២០១៥ និងកូនឈ្មោះ [redacted] ហុងសេង ភេទប្រុស កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨។

-ប្រគល់ដីកសិកម្មដែលមានវិញ្ញាបនបត្រលេខ: ២១០២១២១០-០៥០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តតាកែវ ឱ្យដើមចោទឈ្មោះ [redacted] ស្រីម៉ី។

-បង្គាប់ឱ្យចុងចម្លើយប្រគល់ប្រាក់ USD ៥០.០០០$ (ប្រាំម៉ឺន) ដុល្លារអាមេរិក ឱ្យទៅដើមចោទឈ្មោះ [redacted] ស្រីម៉ី ជាប្រាក់លក់ដីលំនៅឋានពុះជាដីឡូតិ៍បានក្នុងអំឡុង ឆ្នាំ២០១៨ ចំនួនលើសពី USD ១០០.០០០$ (ដប់ម៉ឺន) ដុល្លារអាមេរិក ដែលចុងចម្លើយកាន់កាប់។

-សម្ភារៈផលិតទឹកកកអនាម័យ ផ្សេងៗ រួមទាំងឃ្លាំង និងរថយន្ត៣គ្រឿង មានតម្លៃប្រមាណ USD ១០០.០០០$ (ដប់ម៉ឺន) ដុល្លារអាមេរិក ទៅដើមចោទ ឈ្មោះ [redacted] ស្រីម៉ី។

-ប្រាក់កម្ចីមានការប្រាក់នៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ និងនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ គិតត្រឹមដើមខែធ្នូ ឆ្នាំ២០២១ សរុបប្រមាណ USD ១៦.៧៤៣,០២$ (មួយម៉ឺនប្រាំមួយពាន់ប្រាំពីររយសែសិបបីដុល្លារអាមេរិក និងសូន្យពីរសេន) បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សុខអៀង ជាអ្នកមានកាតព្វកិច្ចសងទាំងអស់។

តាំងពីរៀបអាពាហ៍ពិពាហ៍មក គឺនៅក្នុងក្រុមគ្រួសាររស់នៅមិនចុះសម្រុងនិងគ្នានោះទេ ចេះតែឈ្លោះប្រកែកគ្នា ខ្វែងគំនិតគ្នា ជាពិសេសទៅទៀតនោះ ភាគីចុងចម្លើយមិនបានគិតខ្វល់ខ្វាយអំពីជីវៈភាពប្រពន្ធកូនក្នុងគ្រួសារនោះទេ នៅក្នុងកំឡុងអាពាហ៍ពិពាហ៍នេះ ខ្លួន និងចុងចម្លើយ មានទ្រព្យសម្បត្តិរួមដូចជា៖ ដីកសិកម្មដែលមានវិញ្ញាបនបត្រលេខ៖ ២១០២១២១០-០៥០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយ៍កម្ម សំណង់ និងសុរិយោដីខេត្តតាកែវ, ប្រាក់លក់ដីពុះជាឡូតិ៍ដែលជាទ្រព្យរួមលក់បានក្នុងកំឡុងឆ្នាំ២០១៨ ចំនួនលើសពី USD ១០០,០០០ (ដប់ម៉ឺនដុល្លារអាមេរិក) ដែលចុងចម្លើយកាន់ក្ដាប់ព្រមទាំងសម្ភារៈផលិតទឹកកកអនាម័យរួមទាំងឃ្លាំង និងរថយន្តចំនួន ៣គ្រឿង ដែលមានតម្លៃប្រមាណ USD ១០០,០០០ (ដប់ម៉ឺនដុល្លារអាមេរិក)។ មួយវិញទៀតក្នុងអាពាហ៍ពិពាហ៍របស់ខ្លួន និងចុងចម្លើយ គឺមានជាប់បំណុលរួម ដែលជាប្រាក់កម្ចីមានការប្រាក់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត កម្ចីកាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ និងនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ គិតត្រឹមដើមខែធ្នូ ឆ្នាំ២០២១ សរុបប្រមាណ USD ១៦,៧៤៣.០២ (មួយម៉ឺនប្រាំមួយពាន់ប្រាំពីររយសែសិបបី ដុល្លារអាមេរិកនិងសូន្យពីរសេន) ដែលខ្លួនកំពុងតែទទួលរ៉ាប់រងសងតែម្នាក់ឯង។ នៅក្នុងអាពាហ៍ពិពាហ៍របស់ខ្លួនរវាងចុងចម្លើយឈ្មោះ [redacted] សុខអៀង តាំងពីរៀបអាពាហ៍ពិពាហ៍មក គឺ នៅក្នុងក្រុមគ្រួសាររស់នៅមិនចុះសម្រុងនិងគ្នានោះទេ ចេះតែឈ្លោះប្រកែកគ្នា ខ្វែងគំនិតគ្នា ជាពិសេសទៅទៀតនោះ ភាគីចុងចម្លើយមិនបានគិតខ្វល់ខ្វាយអំពីជីវៈភាពប្រពន្ធកូនក្នុងគ្រួសារនោះទេ ពោលគឺមិនមានការឧបត្ថម្ភទំនុកបម្រុងចិញ្ចឹមបីបាច់ថែរក្សាកូន និងក្រុមគ្រួសារអោយរីកចម្រើននោះទេ គឺមានតែខ្លួនម្នាក់ឯងគត់ ដែលខិតខំចិញ្ចឹមកូនទាំងពីរនាក់ និងរកស៊ីដោះបំណុលរួមដែលបានខ្ចីប្រាក់មានការប្រាក់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ហើយចុងចម្លើយបានយកប្រាក់ទាំងនេះទៅរកស៊ីទឹកកកអនាម័យដោយមិនបានជួយបង់ការប្រាក់ និងប្រាក់ដើមនោះទេ។ កន្លងមកចុងចម្លើយបានគំរាមកំហែងថានិងអាកសម្លាប់ខ្លួន និងវាយសម្ភារៈផ្ទះបាយ និងសម្ភារៈប្រើប្រាស់ក្នុងផ្ទះ ហើយនៅយប់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ៨ ចុងចម្លើយបានវាយធ្វើបាបកូនឈ្មោះ [redacted] ហុងសេង ភេទប្រុស កើតឆ្នាំ២០១៨ បណ្ដាលអោយបែកឈាមមាត់។ នៅក្នុងអំឡុងឆ្នាំ២០១៨ ខ្លួន និងចុងចម្លើយ បានលក់ដីលំនៅឋានដោយពុះជាឡូតិ៍ បានប្រាក់លើសប្រមាណ USD ១០០,០០០ (ដប់ម៉ឺនដុល្លារអាមេរិក) គឺចុងចម្លើយមិនបាន អោយខ្លួនដែលជាប្រពន្ធកាន់កាប់នោះទេ គឺចុងចម្លើយកាន់ក្ដាប់តែម្នាក់ឯង និងមិនព្រមយកប្រាក់នោះទៅសងបំណុលនោះទេទុកអោយខ្លួនរ៉ាប់រងសងតែម្នាក់ឯង។

-មេធាវី [redacted] ខ្លួនសុំធ្វើសេចក្តីថ្លែងការណ៍ថា: ចំពោះដីកម្មសិទ្ធិដែលមានវិញ្ញាបនបត្រលេខ ២១០២១២១០-០៥០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ កូនក្តីខ្លួនសុំគ្រប់គ្រងដោយហេតុផលថាកន្លងមក កូនក្តីខ្លួនបានលក់ដីដែលជាកេរ្តិ៍របស់ឪពុកម្តាយយកទៅរកស៊ីអាជីវកម្មទឹកកក ហើយផលដែលបានពីអាជីវកម្មទឹកកកនេះ ចុងចម្លើយមិនបានផ្តល់មកគ្រួសារ ឬបង្ហាញតួលេខដល់គ្រួសារទេ គឺចុងចម្លើយជាអ្នកទុកដាក់តែម្នាក់ឯង។ ហេតុដូច្នេះ ខ្លួនជាមេធាវីត្រូវតែរក្សាឆន្ទៈរបស់កូនក្តីខ្លួនក្នុង

ការសុំគ្រប់គ្រងនេះ ហេតុផលមួយទៀតពាក់ព័ន្ធនឹងការលះបង់ការទាមទាររបស់កូនក្តីខ្លួនលើប្រាក់លក់ដីឡូត៍ ដោយសារកូនក្តីខ្លួនគាត់ចង់គ្រប់គ្រងលើ ដីដែលមាន វិញ្ញាបនបត្រលេខ ២១០២១២១០-០៥០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ នេះឯង។ ចំណែកការ ស្នើសុំសិទ្ធិ អំណាចមេបាលើកូនទាំងពីររបស់កូនក្តីខ្លួន មានហេតុផលថា ក្មេងទើបតែអាយុនៅក្រោម ១០ឆ្នាំ ត្រូវការម្តាយចិញ្ចឹមបីបាច់ថែរក្សាផ្ទាល់ និងផ្តល់ការរៀនសូត្រ ព្រោះថាសព្វថ្ងៃនេះកូនក្តីខ្លួន កំពុងមើលថែកូនរបស់គាត់ទាំងពីរ និងអាចឱ្យកូនរបស់គាត់ក្លាយជាពលរដ្ឋល្អ និងមានចំណេះដឹងនាថ្ងៃអនាគត។ ម្យ៉ាងទៀតកូនក្តីខ្លួនអាចផ្តល់ភាពកក់ក្តៅដល់កូន ហើយក្មេងមិនគួរឱ្យរស់នៅបែកគ្នាពីបងប្អូននោះទេ ហើយកន្លងមកចុងចម្លើយមានប្រើអំពើហិង្សាលើកូនដែលជាគំរូមិនល្អនៅក្នុងសង្គម ប្រសិនបើតុលាការធ្វើការបែងចែកក្មេងឱ្យរស់នៅបែកគ្នានោះ ក្មេងនឹងខ្វះភាពកក់ក្តៅ។ ចំណែកការអះអាងរបស់ចុងចម្លើយ ដែលទាមទារគ្រប់គ្រងកូនមួយណាក៏បាននោះគឺគាត់ថ្លែងការណ៍ដោយមិនសមស្របនោះទេ ពុំមានជំហរច្បាស់លាស់ជាឪពុកក្នុងការសុំ និងមើលថែគ្រប់គ្រងកូនទេ។ ចំពោះដីឡូត៍ដែលចុងចម្លើយបានថ្លែងការណ៍ ពិតជាមានអង្គហេតុនេះពិតមែន ហើយផលបានពីលក់ដីឡូត៍នេះ បានប្រាក់ជាង១០ម៉ឺនដុល្លារអាមេរិក ប៉ុន្តែចុងចម្លើយមិនបានយកលុយនោះមកឱ្យប្រពន្ធនោះទេ បែរជាយកទៅប្រើប្រាស់ចាត់ចែងខ្លួនឯង។ ប៉ុន្តែការទាមទារនេះកូនក្តីខ្លួនឈប់ទាមទារហើយ ដោយកូនក្តីខ្លួនលះបង់ការទាមទារប្រាក់ ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ដែលជាប្រាក់លក់ដីលំនៅដ្ឋានពុះជាដីឡូត៍បានក្នុងអំឡុងឆ្នាំ២០១៨ ដែលមានចំនួនលើសពី ១០០,០០០$ (ដប់ម៉ឺន) ដុល្លារអាមេរិក ដែលចុងចម្លើយលក់ដីបាន ហើយចុងចម្លើយឯកភាពតាមការលះបង់នេះ។ ចំពោះសម្ភារៈផលិតទឹកកកអនាម័យ ឃ្លាំង ធុងផ្សេងៗ និងរថយន្ត៣គ្រឿង (គិតជាប្រាក់ ជាង១០ម៉ឺនដុល្លារអាមេរិក) បានពីទីតាំងទៅកន្លែងផ្សេង ប៉ុន្តែកូនក្តីខ្លួនមិនទាមទារពីចុងចម្លើយ នោះទេគឺសុំលះបង់ការទាមទារ។

ក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ខ្លួនស្នើសុំតុលាការចេញសាលក្រមប្រគល់ដីកសិកម្ម ដែលមានវិញ្ញាបនបត្រលេខ ២១០២១២១០-០៥០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ មកឱ្យកូនក្តីខ្លួនជាម្ចាស់កម្មសិទ្ធិ។ ចំពោះបំណុលកូនក្តីរបស់ខ្លួនជាអ្នកបង់ ប៉ុន្តែពេលមានរឿងក្តីលែងលះនេះកើតឡើងចុងចម្លើយបានជួយចូលរួមបង់លុយធនាគារបាន ៧ ទៅ ៨ខែ តាំងពីខ្វីរហូតមកដល់បច្ចុប្បន្ន ហើយបំណុលនេះគឺសុំឱ្យចុងចម្លើយជាអ្នកទទួលខុសត្រូវបង់ទាំងអស់។

-មេធាវី [redacted] ខ្លួនសុំធ្វើសេចក្តីថ្លែងការណ៍ថា: ទាក់ទងនឹងការបែងចែកកូន ដូចដែលសហភាគាខ្លួនបានលើកឡើងហើយ ថាកូនរបស់កូនក្តីរបស់ខ្លួនមានអាយុក្រោម១០ ឆ្នាំ នៅពេលដែលឪពុកម្តាយលែងលះគ្នា គឺធ្វើឱ្យមានការប៉ះទង្គិចផ្លូវចិត្តកូនធ្ងន់ធ្ងរ ហើយបើក្មេងរស់នៅបែកបងប្អូនគឺធ្វើឱ្យប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរបន្ថែមទៀត។ ហើយកន្លងមកចុងចម្លើយ បាន ប្រើប្រាស់អំពើហិង្សាលើកូន ហើយបច្ចុប្បន្នចុងម្លើយពុំមានពេលគ្រប់គ្រាន់ដើម្បីមើលថែកូន និង ទាំងជីវភាពចុងចម្លើយក៏បានលើកឡើងហើយថា គាត់ពុំមានលទ្ធភាពបង់ធនាគារ ដោយសារគាត់រកប្រាក់ចំណូលមិនសូវបាន ចុះប្រសិនបើឱ្យកូនៗទៅគាត់ តើគាត់មានពេលវេលាអាចមើលថែកូន និងលទ្ធភាពគ្រប់គ្រាន់ផ្គត់ផ្គង់កូនដែរឬទេ? ដូច្នេះទាក់ទងនឹងលទ្ធភាព ពេលវេលា គឺកូនៗត្រូវតែរស់នៅជាមួយម្តាយមានភាពកក់ក្តៅជាង និងបងប្អូនត្រូវរស់នៅជុំគ្នាគឺកាន់តែមានភាពកក់ក្តៅ។

**៣.២-ចុងចម្លើយឈ្មោះ [redacted] សុខអៀង** បានធ្វើថ្លែងការណ៍តបថា: សុំឱ្យតុលាការចេញសាលក្រមសម្រេចដូចការទាមទារក្នុងកម្មវត្ថុខាងក្រោម៖

-សុំមិនយល់ស្របតាមការសុំលែងលះរបស់ដើមចោទទេ លើកលែងតែធ្វើការបែងចែកដី និងបំណុលរួមទាំងកូនឱ្យច្បាស់សិន។

-សុំសិទ្ធិគ្រប់គ្រងកូនម្នាក់កូនមួយណាក៏បាន ព្រោះខ្លួនក៏ស្រឡាញ់កូនដែរ ចង់មើលថែកូនផ្ទាល់ ចង់ឱ្យមានភាពកក់ក្តៅរវាងឪពុក។

-ដីកសិកម្មដែលមានវិញ្ញាបនបត្រលេខ ២១០២១២១០-០៥០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ



Scanned with CamScanner

២០២០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី ខេត្តតាកែវ ខ្លួនសុំលក់ ដើម្បីបង់ប្រាក់ដែលនៅជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ និងនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ គិតត្រឹមដើមខែធ្នូ ឆ្នាំ២០២១ សរុបប្រមាណ ១៦,៧៤៣,០២ (មួយម៉ឺនប្រាំមួយពាន់ប្រាំពីរសែសិបបី ដុល្លាអាមេរិក និងពីរសេន) ប្រាក់ដែល នៅសល់ចែកជាពីរចំណែកស្មើគ្នា។

-ខ្លួនឯកភាពតាមការអះអាងរបស់ដើមចោទលើចំណុចទី៤ និងចំណុចទី៥។

តាមការអះអាងរបស់ដើមចោទគឺត្រឹមត្រូវ ពិតជាមានការលក់កេរ្តិ៍របស់ដើមចោទ ដើម្បីមករកស៊ីទឹកកកអនាម័យ និងខ្ចីប្រាក់ខ្លះទៀតរបស់ម្តាយរបស់ខ្លួនមករកស៊ីពិតមែន។ ការអះអាងរបស់ដើមចោទថា ខ្លួនវាយកូនដល់បែកឈាម គឺខ្លួនមិនមានចេតនាធ្វើបាបកូនទេ គ្រាន់តែពេលនោះកូនវាជណ្តើមរបស់លេងគ្នា ហើយខ្លួនទះចំច្រមុះវាបណ្តាលឱ្យចេញឈាម ចំណែកឯដើមចោទក៏ធ្លាប់វ៉ៃកូនដូចគ្នា។

ការលើកឡើងរបស់លោកមេធាវី ចំពោះការបង់ធនាគារអាចមានភាពខុសគ្នាតិចតួចគ្មានបញ្ហាទេ។

ហើយចំពោះដីកសិកម្មដែលមានវិញ្ញាបនបត្រលេខ ២១០២១២១០-០៥០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ ខ្លួនស្នើសុំទាមទារបែងចែកពាក់កណ្តាល។ ចំពោះបំណុលខ្លួនស្នើសុំបែងចែកពាក់កណ្តាលម្នាក់កន្លះមកខ្លួនបានចូលរួមបង់រហូត ប៉ុន្តែមកដល់ពេលនេះខ្លួនមិនបានជួយបង់នោះទេ ខ្លួនស្នើសុំឱ្យលក់ដីកសិកម្មដែលមានវិញ្ញាបនបត្រលេខ ២១០២១២១០-០៥០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ យកមកសងបំណុលធនាគារទាំងអស់ ហើយសល់ប៉ុន្មានចែកគ្នាពាក់កណ្តាល។ ចំពោះកូនពីមុនខ្លួនសុំទាមទារយកកូនម្នាក់មួយណាក៏បាន ប៉ុន្តែពេលនេះខ្លួនសុំទាមទារកូនម្នាក់ឈ្មោះ [redacted] ហុងសេង ភេទប្រុស ខ្លួនមិនចាំថាកើតថ្ងៃណាទេ ទាល់តែមើលសំបុត្រកំណើត មូលហេតុកូននេះគឺរស់នៅជាមួយខ្លួនច្រើន ហើយខ្លួនមើលវាជិតដល់ ហើយសព្វថ្ងៃកូនគឺតាមខ្លួន ហើយខ្លួនធ្លាប់ឱ្យកូនទៅរៀនដែរ ប៉ុន្តែកូនវាមិនចង់ចូលរៀន។ ខ្លួនស្នើសុំសិទ្ធិអំណាចមេបាលើកូនម្នាក់ដូចការទាមទារខាងលើ។

**៣.៣-ដើមចោទឈ្មោះ** [redacted] **ស្រីមុំ** ខ្លួនសូមធ្វើសេចក្តីថ្លែងការណ៍តបថា៖ ខ្លួនសុំរក្សាការទាមទារដែលបានថ្លែងការណ៍ខាងលើទុកនៅដដែល និងសុំឱ្យតុលាការសម្រេចតាមការទាមទាររបស់ខ្លួនផងចុះ។

**៤-ការប្រាស្រ័យទាក់ទង**

ការប្រាស្រ័យទាក់ទងកូន គូភាគីមិនបានលើកឡើង និងមិនព្រមព្រៀងគ្នាអំពីអ្នកមានអំណាចមេបានោះទេ ដូច្នេះការប្រាស្រ័យទាក់ទងកូន គប្បីតុលាការសម្រេច និងពិចារណាតាម ច្បាប់។

**ឯកសារភស្តុតាង ដែលគូភាគីដាក់ជូនតុលាការពិនិត្យ**

-សំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២។

-សេចក្តីចម្លងសំបុត្រកំណើត ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៦ របស់កូនឈ្មោះ [redacted] ម៉េងហាន។

-សំបុត្រកំណើត ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ របស់កូនឈ្មោះ [redacted] ហុងសង។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ២១០២១២១០-០៥០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ។

-កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០។

-កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១។

-កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១២។

-កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៣។

**៥-ចំណុចគ្មានវិវាទ និងចំណុចវិវាទ**

**៥.១-ចំណុចគ្មានវិវាទ-គ្មាន**

-ដើមចោទ និងចុងចម្លើយព្រមព្រៀងគ្នាសងបំណុលដែលនៅជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញ

វត្ថុអម្រឹត កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ និងនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ គិតត្រឹមដើមខែធ្នូ ឆ្នាំ២០២១ សរុបប្រមាណ ១៦,៧៤៣.០២ (មួយម៉ឺនប្រាំមួយពាន់ប្រាំ ពីររយសែសិបបីដុល្លារអាមេរិក និងពីរសេន) ម្នាក់ពាក់កណ្ដាល។

-ដើមចោទលះបង់ការទាមទារប្រាក់ ៥០,០០០$ (ប្រាំម៉ឺន)ដុល្លារអាមេរិក ដែលជាប្រាក់លក់ដីលំនៅឋានពុះជាជីឡូត៍បានក្នុងអំឡុងឆ្នាំ២០១៨ ដែលមានចំនួនលើសពី ១០០,០០០$ (ដប់ម៉ឺន) ដុល្លារអាមេរិក ដែលចុងចម្លើយលក់ដីបានហើយ ចុងចម្លើយឯកភាពតាមការលះបង់ នេះ។

-ដើមចោទលះបង់ការទាមទារសម្ភារៈផលិតទឹកកកអនាម័យ ផុងផ្សេងៗ រួមទាំងឃ្លាំង និងរថយន្តបីគ្រឿង មានតម្លៃប្រមាណ ១០០,០០០$ (ដប់ម៉ឺន) ដុល្លារអាមេរិក ហើយចុងចម្លើយឯកភាពតាមការលះបង់នេះ។

**៥.២. ចំណុចវិវាទ**

-តើមូលហេតុដែលដើមចោទទាមទារលែងលះពីចុងចម្លើយ ត្រឹមត្រូវតាមច្បាប់ដែរ ឬទេ? -ភាគីដើមចោទសុំសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់ ឯភាគីចុងចម្លើយបដិសេធ និងសុំសិទ្ធិអំណាចមេបាលើកូនម្នាក់មួយ។ តើការកំណត់សិទ្ធិអំណាចមេបាលើកូនទៅឱ្យភាគីណាមួយដែលនាំឱ្យកូនទទួលបានអត្ថប្រយោជន៍ច្រើនជាង?

-តើដីដែលមានវិញ្ញាបនបត្រលេខ ២១០២១២១០-០៥០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី ខេត្តតាកែវ ជាទ្រព្យសម្បត្តិរួមដែលជាកម្មវត្ថុក្នុងការទាមទារបែងចែករបស់ភាគីដែរឬទេ?

## សំអាងហេតុ

ក្រោយពីបានស្ដាប់សេចក្ដីថ្លែងការណ៍របស់ដើមចោទ និងចុងចម្លើយនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចមកឃើញថា ៖

១-ពាក្យបណ្ដឹងលែងលះលេខ ១៦៧៥ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ របស់ដើមចោទឈ្មោះ [redacted] ស្រីម៉ី តុលាការអាចលើកយកមកធ្វើការទាញហេតុផលដោយផ្ទាល់មាត់បានតាមបញ្ញត្តិមាត្រា ៩ និងមាត្រា ២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-តាមសេចក្ដីថ្លែងការណ៍របស់គូភាគី និងការពិនិត្យភស្តុតាងជាឯកសារដែលមានក្នុងសំណុំរឿងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា ៖

**២.១-ឈ្មោះ [redacted] ស្រីម៉ី** និងឈ្មោះ **[redacted] សុខអៀង** ពិតជាបានរៀបអាពាហ៍ពិពាហ៍ និងគ្នាតាមប្រពៃណី និងបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ១២ ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ត្រឹមត្រូវទៅតាមច្បាប់។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ រវាងខ្លួន និងចុងចម្លើយ គឺមានកូនចំនួន ២នាក់ មានឈ្មោះ [redacted] **ម៉េងហាន** ភេទ ប្រុស កើតថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ និងឈ្មោះ [redacted] **ហុងសេង** ភេទប្រុស កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨។ ហើយនេះជាហេតុធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាស្រឡាញ់គ្នាជាប្ដីប្រពន្ធទៅ អនាគតទៅទៀតហើយ។ ភាគីដើមចោទប្ដឹងសុំលែងលះពីចុងចម្លើយ ហើយភាគីចុងចម្លើយមិនបានឯកភាពតាមការប្ដឹងសុំលែងលះពីភាគីដើមចោទនោះទេ ប៉ុន្តែភាគីដើមចោទនៅតែសុំឱ្យតុលាការចេញសាលក្រមតាមការទាមទារដូចមានក្នុងកម្មវត្ថុខាងលើ តុលាការយល់ឃើញថា ទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ភាគីទាំងសងខាងបានបែកបាក់ ហើយគ្មានសង្ឃឹមនឹងអាចបដិទានឡើងវិញបានឡើយ។

**២.២-អំពីអំណាចមេបា**

ដើមចោទឈ្មោះ [redacted] **ស្រីម៉ី** និងចុងចម្លើយឈ្មោះ [redacted] **សុខអៀង** មិនបានព្រមព្រៀងគ្នាអំពីការគ្រប់គ្រងកូន និងអំណាចមេបាលើកូនទាំងពីរគឺឈ្មោះ [redacted] **ម៉េនហាន** ភេទប្រុស កើតថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៥ ជនជាតិខ្មែរ និងកូនឈ្មោះ [redacted] **ហុងសេង** ភេទប្រុស កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ ភាគីដើមចោទប្ដឹងសុំសិទ្ធិអំណាចមេបាលើកូនប្រុសទាំងពីរខាងលើ ចំណែកឯភាគីចុង

ចម្លើយថ្លែងការណ៍សុំទាមទារសិទ្ធិអំណាចមេបាលើកូនប្រុសម្នាក់ឈ្មោះ [redacted] ហុងសេង ភេទប្រុស កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ ដោយមិនបានព្រមព្រៀងគ្នានោះទេ។ ក្នុងដំណាក់កាលមុនៗ ចុងចម្លើយបានសុំទាមទារកូនម្នាក់មួយណាក៏បានដើម្បីមកស្ថិតក្រោមសិទ្ធិអំណាចមេបារបស់ខ្លួន តែក្រោយមកចុងចម្លើយក៏ប្តូរមកទាមទារកូនឈ្មោះ [redacted] ហុងសេង ភេទប្រុស ដោយមិនបានចាំថ្ងៃ ខែឆ្នាំកំណើតកូនទេទាល់តែមើលសំបុត្រកំណើតរបស់កូនឈ្មោះ [redacted] ហុងសេង ទើបដឹង។ ទាំងនេះ បញ្ជាក់ឱ្យឃើញថាចុងចម្លើយគ្មានបំណងច្បាស់លាស់ និងក្តីយកចិត្តទុកដាក់លើការយកកូនណា មួយទៅទេគឺចង់តែឈ្នះប៉ុណ្ណោះ។ គប្បីតុលាការពិចារណា ទៅលើផលប្រយោជន៍របស់កូនតាម បញ្ញត្តិមាត្រា **១០៣៧ ចំណុច ៣** នៃក្រមរដ្ឋប្បវេណី។

**៣-កំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទងកូន និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីថែរក្សាកូន**

៣.១-ដើមចោទឈ្មោះ [redacted] **ស្រីមុំ** និងចុងចម្លើយឈ្មោះ [redacted] **សុខអៀង** មិនបានពិភាក្សាគ្នា ក្នុងការប្រាស្រ័យទាក់ទងកូននោះទេ។ គប្បីតុលាការពិចារណា និងសម្រេចសេចក្តីតាមច្បាប់។

៣.២-ចំពោះសោហ៊ុយចាំបាច់ ដែលត្រូវទទួលបន្ទុកដើម្បីថែរក្សាកូន ដោយដើមចោទ និង ចុងចម្លើយ មិនបានលើកឡើងមកពិភាក្សា និងព្រមព្រៀងគ្នានោះទេ។ គប្បីតុលាការមិនលើកយក មកពិចារណា និងសម្រេចសេចក្តីឡើយ។

**៤-តុលាការកំណត់អំពីអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី**

ដើម្បីជៀសវៀងការប្រកួតប្រជែងទាក់ទង និងការសន្មត់បិតុភាពរបស់កូនផ្អែកតាមបញ្ញត្តិ មាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី អំឡុងពេលប្រកួតប្រជែងគ្នានេះគឺ១២០ថ្ងៃ។ ដូច្នេះការរៀបអាពាហ៍ពិពាហ៍ថ្មីនៅក្នុងអំឡុងនេះត្រូវបានកំរិត។

**៥-ការបែងចែកទ្រព្យសម្បត្តិ**

៥.១-ចំពោះទ្រព្យរួមដីកសិកម្មដែលមានវិញ្ញាបនបត្រលេខ: ២១០២១២១០-០៥០៧ ចុះ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ ភាគីដើមចោទស្នើសុំសិទ្ធិគ្រប់គ្រង និងឱ្យចុងចម្លើយប្រគល់ដីមកឱ្យខ្លួន ប៉ុន្តែភាគីចុង ចម្លើយបានបដិសេធ មិនព្រមប្រគល់ដីកសិកម្មខាងលើទៅឱ្យដើមចោទនោះទេ គឺចុងចម្លើយ ស្នើសុំលក់ដីកសិកម្មខាងយកមកសងធនាគារទាំងអស់ ប្រសិនបើនៅសល់នឹងបែងចែកម្នាក់ ពាក់កណ្តាល។ តុលាការយល់ឃើញថា៖

-ដើមចោទទាមទារឱ្យចុងចម្លើយប្រគល់ប្រាក់ ៥០,០០០$ (ប្រាំម៉ឺន) ដុល្លារអាមេរិក ដែល ចុងចម្លើយបានកាន់កាប់ជាប្រាក់លក់ដីលំនៅឋានពុះជាដីឡូត៍បាន ក្នុងអំឡុង ឆ្នាំ២០១៨ ដែលមាន ចំនួនលើសពី ១០០,០០០$ (ដប់ម៉ឺន)ដុល្លារអាមេរិក យកវិញ ប៉ុន្តែដើមចោទមិនទាមទារនោះទេ ហើយចុងចម្លើយក៏បានឯកភាពតាមដែរ។

-ចំពោះសម្ភារៈផលិតទឹកកកអនាម័យ ផុងផ្សេងៗ រួមទាំងឃ្លាំង និងរថយន្តបីគ្រឿង មាន តម្លៃប្រមាណ ១០០,០០០$ (ដប់ម៉ឺន) ដុល្លារអាមេរិក ដើមចោទទាមទារឱ្យចុងចម្លើយប្រគល់ប្រាក់ ៥០០០០$ (ប្រាំម៉ឺន) ដុល្លារអាមេរិក ប៉ុន្តែដើមចោទមិនទាមទារ ហើយចុងចម្លើយឯកភាពតាមដែរ។

ដោយសារការមិនទាមទារទាំងពីរចំណុចខាងលើនេះ ដើមចោទគប្បីទទួលបាននូវដី កសិកម្មដែលមានវិញ្ញាបនបត្រលេខ២១០២១២១០-០៥០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញ ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ ជាការតបស្នងនឹងការមិន ទាមទារនោះ។

៥.២-ចំពោះបំណុលដែលភាគីដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាសងបំណុល ដែលនៅជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ និងនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ គិតត្រឹមដើមខែធ្នូ ឆ្នាំ២០២១ សរុបប្រមាណ ១៦,៧៤៣.០២ (មួយម៉ឺនប្រាំមួយ ពាន់ប្រាំពីររយសែសិបបីដុល្លារអាមេរិក និងពីរសេន) ម្នាក់ពាក់កណ្តាល។ ណាមួយតុលាការមិន អាចសម្រេចកំណត់ភាគីណាមួយឱ្យទទួលខុសត្រូវលើបំណុលជំនួសម្ចាស់បំណុលបានឡើយ។



Scanned with CamScanner

៦-ចំពោះប្រាក់ប្រដាប់ក្តីភាគីដើមចោទ និងចុងចម្លើយមិនបានលើកឡើង និងធ្វើការស្នើសុំនោះទេ គប្បីតុលាការពិចារណា និងសម្រេចសេចក្តីតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**សេចក្តីសម្រេចបញ្ចប់**

១-ឱ្យដើមចោទឈ្មោះ [redacted] ស្រីមុំ លែងលះពីចុងចម្លើយឈ្មោះ [redacted] សុខអៀង។

-ឱ្យភាគីដើមចោទឈ្មោះ [redacted] ស្រីមុំ ស្ថិតនៅក្នុងភាពជាមេម៉ាយរយៈពេល ១២០ថ្ងៃ គិតពីថ្ងៃអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល។

២-ឱ្យដើមចោទឈ្មោះ [redacted] ស្រីមុំ ជាមានសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់ គឺឈ្មោះ [redacted] ម៉េងហាន ភេទប្រុស កើតថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ និងកូនឈ្មោះ [redacted] ហុងសេង ភេទប្រុស កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨។

**របៀបប្រាស្រ័យទាក់ទងកូន:** អ្នកដែលមិនមានសិទ្ធិអំណាចមេបាលើកូន អាចចូលជួបប្រាស្រ័យទាក់ទងកូនបានតាមការពិភាក្សាគ្នា និងភាគីដែលមានសិទ្ធិអំណាចមេបាលើកូន ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីដែលគ្មានសិទ្ធិអំណាចមេបាលើកូន ក្នុងការចូលជួបប្រាស្រ័យទាក់ទងកូន។

៣-ឱ្យដើមចោទឈ្មោះ [redacted] ស្រីមុំ មានសិទ្ធិគ្រប់គ្រងដីកសិកម្ម ដែលមានវិញ្ញាបនបត្រលេខ: ២១០២១២១០-០៥០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តតាកែវ។

៤-ចំណុចទាមទារលើសពីនេះច្រានចោល។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ៥០% និងចុងចម្លើយ ៥០%។

៦-សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ ចំពោះមុខគូភាគី ។

-ទុកសិទ្ធិប្តឹងជំទាស់តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅកំពង់ស្ពឺ, ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]